# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្ដាហ៍ លេខ ៤៣

នាសប្ដាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការត្រឹមតែពីរថ្ងៃប៉ុណ្ណោះ ដើម្បីទុកពេលវេលាដល់ភាគីទាំងអស់ត្រៀមរបៀបចំសម្រាប់សវនាកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង០០២ វគ្គ១។ នាសប្ដាហ៍នេះ សាក្សីជំនាញលោក **អ៊ីសា អូស្មាន** (**Ysa Osman**) បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្ដល់សក្ខីកម្មស្ដីពីការប្រព្រឹត្តមកលើជនជាតិភាគតិចចាម ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។[1] លោក **អូស្មាន** សព្វថ្ងៃមានមុខងារជាអ្នកវិភាគនៅក្នុងការិយាល័យសហចៅក្រមស៊ើបសួរ (**OCIJ**) ហើយធ្លាប់

---

[1] សាក្សីជំនាញត្រូវតម្រូវអោយផ្ដល់នូវមតិយោបល់ និងការបកស្រាយបំភ្លឺលើបញ្ហាបច្ចេកទេសជាក់លាក់ផ្សេងៗដែលយល់ឃើញថាមានសារៈសំខាន់ចាំបាច់ដល់កិច្ចដំណើរការនីតិវិធីសវនាការ (សូមមើល វិធាន ៣១(១) នៃវិធានផ្ទៃក្នុង)។ អ្នកជំនាញត្រូវបានតែងតាំងដោយដីកាសម្រេចរបស់តុលាការ ដោយមានចែងយ៉ាងច្បាស់ពីភារកិច្ចរបស់អ្នកជំនាញ (សូមមើល វិធាន ៣១(៣) នៃវិធានផ្ទៃក្នុង)។ អង្គជំនុំជម្រះ ត្រូវសម្រេចអំពីតួនាទីរបស់សាក្សីជំនាញដែលត្រូវជួយបំភ្លឺដល់អង្គជំនុំជម្រះលើបញ្ហាបច្ចេកទេសជាក់លាក់ផ្សេងៗ ដែលទាមទារនូវចំណេះដឹងពិសេសនៅក្នុងវិស័យជាក់លាក់មួយ។ សាក្សីជំនាញ មានសិទ្ធិបញ្ចេញមតិយល់ឃើញរបស់ខ្លួន និងអាចផ្ដល់ចម្លើយប៉ាន់ស្មានកម្រិតក្នុងករណីដែលមានការជូនដំណឹងពីចំណេះដឹងទូលាយរបស់សាក្សីជំនាញ ស្ដីពីប្រធានណាមួយតែប៉ុណ្ណោះ។ (សូមមើល អង្គជំនុំជម្រះសាលាដំបូង "*សេចក្ដីសម្រេចលើការចាត់តាំងអ្នកជំនាញ*" (ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២) លេខ E215, [ពីនេះតទៅហៅថា **សេចក្ដីសម្រេចស្ដីពីអ្នកជំនាញ**]។ ក៏ប៉ុន្តែ សេចក្ដីសម្រេចនេះ ក៏បានកំណត់ផងដែរថា "សាក្សីជំនាញមិនអាចផ្ដល់មតិយោបល់លើបញ្ហាអង្គហេតុស្នូលនានានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទឡើយ ដោយហេតុថា មានតែអង្គជំនុំជម្រះប៉ុណ្ណោះ ដែលមានសមត្ថកិច្ចសម្រេចសេចក្ដីតាមផ្លូវតុលាការលើបញ្ហាទាំងនេះនៅក្នុងរឿងក្ដី។" សេចក្ដីសម្រេចចុះនៅខែកក្កដា ឆ្នាំ២០១២ ផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ (ជាឧទាហរណ៍ សូមមើល អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង រដ្ឋអាជ្ញាទល់នឹងការេម៉េរ៉ា (Prosecutor v. Karemera) សេចក្ដីសម្រេចលើញត្តិរបស់ ចូសេហ្វ ហ្ស៊ីរ៉ូរេរ៉ា (Joseph Nzirorera) ស្នើសុំកម្រិតវិសាលភាពនៃសក្ខីកម្មរបស់សាក្សី

បានបម្រើការងារកន្លងមកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (**ហៅកាត់ថា ឌី.ស៊ី.ខេម**) ហើយគាត់ក៏ជាអ្នកនិពន្ធសៀវភៅពីរក្បាល ស្តីពីជនជាតិចាមដែលបានបោះពុម្ពផ្សាយដោយ **ឌី.ស៊ី.ខេម** មានដូចជា៖ សៀវភៅ "អូកូបា" និងសៀវភៅ "ការបះបោររបស់ចាម" ។[2] ដោយផ្អែកទៅលើការស្រាវជ្រាវរបស់គាត់ លោក **អូស្មាន** អាចផ្តល់នូវព័ត៌មានយ៉ាងច្រើនទាក់ទងនឹងប្រវត្តិសាស្ត្ររបស់ជនជាតិចាម និងទិដ្ឋភាពសំខាន់ៗនៃអត្តសញ្ញាណរបស់ជនជាតិចាម។ គាត់ក៏បានផ្តល់សក្ខីកម្មផងដែរ ស្តីពីការបះបោរមួយចំនួនរបស់ចាម ដែលបានកើតឡើងនៅ ភូមិទ្រា ភូមិកោះផល និងភូមិស្វាយឃ្លាំង ហើយគាត់ក៏បានពន្យល់ពីការប៉ានស្មានរបស់គាត់ស្តីពីចំនួនជនជាតិចាមដែលរស់នៅកម្ពុជា មុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ លោក **អ៊ីសា អូស្មាន** នឹងត្រលប់មកផ្តល់សក្ខីកម្មវិញនៅខែមីនាខាងមុខនេះ ដើម្បីបញ្ចប់សក្ខីកម្មរបស់គាត់។

[*] របាយការណ៍នេះ ត្រូវបានសរសេរដោយ អាឡិចសាន់ឌឺ បេនហ្ស (Alexander Benz), ជា ប៉ូរ៉ាក់មុន្នី, ខេតលីន កាហ្វ្រៀ (Caitlin McCaffrie), អេលីហ្សាប៊ែត អ័រ (Elizabeth Orr), ធី ស៊ុន (Thi Son), តាយ លីណា និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (THE WSD HANDA Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

ជំនាញ អាលីស៊ុន ដេស ហ្វហ្គេស (Alison Des Forges) និង អេនឌ្រូ ហ្គីឆាអូអា (Andrew Guichaoua) (ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៧) លេខ ICTR-98-44-T កថាខណ្ឌ ៣)។

[2] ចំណងជើងសៀវភៅទីមួយរបស់លោក **អ៊ីសា អូស្មាន** គឺ "អូកូបា (Oukouba)" ជាពាក្យភាសាអារ៉ាប់ ដែលមានន័យថា ទណ្ឌកម្ម និងយុត្តិធម៌។ លោក **អូស្មាន** ប្រាប់អង្គជំនុំជម្រះថា អត្ថន័យដែលគាត់មានបំណងចង់ឆ្លុះបញ្ចាំងក្នុងចំណងជើងនេះគឺ យុត្តិធម៌។